N. 28
28.2.02

ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

២១-២-២០០២ - ព្រះរាជក្រម នស/រកម/០២០២/០០៩ ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាអ៊ុយនីគ្រ័រ ស្ដីពីសម្បត្តិវប្បធម៌ដែលត្រូវគេលួចឬត្រូវគេធ្វើ នីហរណកម្មខុសច្បាប់ ៤៦២

២១-២-២០០២ - ព្រះរាជក្រម នស/រកម/០២០២/០១០ច្បាប់ស្ដីពីការអនុម័តយល់ ព្រមលើពិធីសារជម្រើសពីរ ដកស្រង់ពីអនុសញ្ញាស្ដីពីសិទ្ធិកុមារ អំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ៤៦៤

២. ព្រះរាជក្រឹត្យ

២១-២-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤៥ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ឌឹកស៊ីង** (WANG DEXING) សញ្ជាតិដើមចិន ៤៦៦

២១-២-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤៦ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចិន ស៊ីងហ៊ុង** (CHEN HSING HUNG) សញ្ជាតិដើមចិន ៤៦៧

២២-២-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤៧ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ដល់លោក **ដេនីស មីសែលឡូរ៉ង់** (DENIS MICHEI LAURENT) សញ្ជាតិដើមបារាំង ៤៦៨

២៤-២-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤៨ ស្ដីពីការតែងតាំងឯកឧត្ដមលោកឧកញ៉ា និងលោកជំទាវ ចំនួន០៣រូប ជាទីប្រឹក្សាសម្ដេចជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ៤៦៩

២៥-២-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០២០២/០៤៩ ស្ដីពីការអនុញ្ញាតឱ្យពន្យារអាណត្តិការងាររហូតដល់០៥ ឆ្នាំយ៉ាងយូរ គិតពីថ្ងៃដែលសាមីខ្លួនត្រូវបានតែង តាំងសំរាប់មុខតំណែង អភិបាល អភិបាលរងខេត្ត-ក្រុង និងអភិបាល-អភិបាលរងស្រុក-ខ័ណ្ឌ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ៤៧០

ខ

II- រាជរដ្ឋាភិបាល

១_ អនុក្រឹត្យ

២៥-០២-២០០២	- អនុក្រឹត្យលេខ ១៦អនក្រ.បក ស្តីពីមូលនិធិឃុំ-សង្កាត់	៤៧១
២៦-០២-២០០២	- អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូត	៤៨១
២៧-០២-២០០២	- អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៤៨២
២៨-០២-២០០២	- អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៤៨៣
២៨-០២-២០០២	- អនុក្រឹត្យលេខ ១០៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥១៧
២៨-០២-២០០២	- អនុក្រឹត្យលេខ ១០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥១៩
២៨-០២-២០០២	- អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥២០

២_ សេចក្តីសំរេច

១៨-០២-២០០២	-សេចក្តីសំរេចលេខ ១៤ សសរស្តីពីការបង្កើតគណៈកម្មការចាត់ចែងធ្វើមាតុភូមិនិវត្តន៍ ពីសហរដ្ឋអាមេរិករបស់ជនជាតិកម្ពុជា	៥២១

ព្រះរាជក្រម

នស/រកម/០២០២/០០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអ៊ុយនីដ្រ័រស្តីពីសម្បត្តិវប្បធម៌ ដែលត្រូវគេលួច ឬត្រូវគេធ្វើនីហរណកម្មខុសច្បាប់ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ប៉ុន្តែដែលព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ ព្រោះព្រឹទ្ធសភាពុំអាចដំណើរការប្រជុំពិនិត្យច្បាប់នេះបាន ដោយមូលហេតុខ្វះកូរ៉ុម ។ ច្បាប់នេះមានសេចក្តីទាំងស្រុង ដូចតទៅ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើអនុសញ្ញាអ៊ុយនីដ្រ័រ ស្តីពីសម្បត្តិវប្បធម៌ ដែលត្រូវគេលួច ឬត្រូវគេធ្វើនីហរណកម្មខុសច្បាប់

មាត្រា ១.-

អនុម័តយល់ព្រមលើអនុសញ្ញាអ៊ុយនីដ្រ័រ ស្តីពីសម្បត្តិវប្បធម៌ដែលត្រូវគេលួច ឬត្រូវគេធ្វើនីហរណកម្មខុសច្បាប់ ដែលបានចុះហត្ថលេខា នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅទីក្រុងរ៉ូម នៃសាធារណរដ្ឋអ៊ីតាលី ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរ/ល.០២.០២.០០៥៣ នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ព្រះហស្តលេខា

នរោត្តម បុប្ផាទេវី

លេខ : ៥២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

នស/រកម/០២០២/០១០

ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារជម្រើសពីរ ដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វ-ផ្សាយរូបភាពអាសអាភាសកុមារ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គ លើកទី ៧ នីតិកាលទី ២ ប៉ុន្តែដែលព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ ព្រោះព្រឹទ្ធសភាពុំអាចដំណើរការប្រជុំពិនិត្យច្បាប់នេះបាន ដោយមូលហេតុខ្វះកូរ៉ុម ។ ច្បាប់នេះមានសេចក្តីទាំងស្រុង ដូចតទៅ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើពិធីសារជម្រើសពីរ ដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារជម្រើសពីរ ដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ដែលឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានអនុម័តយល់ព្រមនាសម័យប្រជុំពេញអង្គរបស់ខ្លួនលើកទី ៩៧ ព្រមទាំងបានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខានៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០ នៅទីក្រុងញូវយ៉ក ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារទាំងពីរនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នស/រកម.០២.០២.០០៥៤

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ : ៥៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៣ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឥសាន

ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វាង ឌឹកស៊េង** (WANG DEXING) សញ្ជាតិដើមចិន កើតថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ នៅស្រុកក្វាងចូវ ខេត្តក្វាងទុង ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

៣រស.០២.០២.០០៥៥

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៥១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ អាន

ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចិន ស៊ីងហ៊ុង** (CHEN HSING HUNG) សញ្ជាតិដើមចិន កើតថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៥៨ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវឌី តាន់

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

ពរស.០២.០២-០០៥៦

ព្រះរាជក្រឹត្យ

នស/រកត/0២0២/០៤៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣0 ចុះថ្ងៃទី 0៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់លោក **ដេនីស មីសែល ឡូរ៉ង់** (**DENIS MICHEL** LAURENT) សញ្ជាតិដើមបារាំង កើតថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៦៣ នៅ **Fontainebleau Seine et Marne** នៃសាធារណរដ្ឋបារាំង ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៤៩ ច.ល

ដើម្បីច្បាប់ចំលងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០0២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារ៉ុង ឌី តាន់

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០២

៣រាជ. ០២. ០២. ០០៥៧

ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៧ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម លោកឧកញ៉ា និងលោកជំទាវ ចំនួន ០៣ រូប ជាទីប្រឹក្សារបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ដែលមានរាយនាមដូចខាងក្រោម :

១- ឯកឧត្តម **មីត ជារ៉ា** ទទួលបន្ទុកការងារច្បាប់ ។

២- លោកឧកញ៉ា **កែវ ឡា** ទទួលបន្ទុកការងារវិនិយោគ និង អភិវឌ្ឍន៍ ។

៣- លោកជំទាវ **តាន់ ខួចឆេង** ទទួលបន្ទុកការងារសុខាភិបាល ។

មាត្រា ២ : ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៥៤ ច.ល

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០២

ពរស. ០២.៦២.០០៥៨

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧៣ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការកំណត់អាណត្តិរបស់អភិបាល អភិបាលរង ខេត្ត ក្រុង និង អភិបាល អភិបាលរង ស្រុក ខ័ណ្ឌ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៩/២០៥ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការពន្យារអាណត្តិ សំរាប់អភិបាលរង ខេត្ត ក្រុង ទី ២ និង ទី ៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយពន្យារ អាណត្តិ ការងាររហូតដល់ ៥ ឆ្នាំ យ៉ាងយូរ គិតពីថ្ងៃដែលសាមីខ្លួន ត្រូវបានតែងតាំងសំរាប់មុខតំណែង អភិបាល អភិបាលរង ខេត្ត ក្រុង និង អភិបាល អភិបាលរង ស្រុក ខ័ណ្ឌ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី១ នេះ ។

មាត្រា ២ : ត្រូវទុកជានិរាករណ៍ នូវព្រះរាជក្រឹត្យលេខ នស/រកត/១១៩៩/២០៥ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៥៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ; ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២

៣៧ល.០២.០២.០០៥៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៦ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី មូលនិធិឃុំ សង្កាត់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០០១ដែលប្រកាសអោយប្រើច្បាប់ ស្ដីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងតាមស្មារតីអង្គប្រជុំលើកទី៨របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលបំណងកំណត់ បែបបទ នីតិវិធី នៃការគ្រប់គ្រងមូលនិធិឃុំ សង្កាត់ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ មូលនិធិឃុំ សង្កាត់ហៅកាត់ថា " មូលនិធិ " ។

មាត្រា ២.-

មូលនិធិមានគោលបំណង ដូចខាងក្រោម:

- ធ្វើអោយឃុំ សង្កាត់ អាចរ៉ាប់រងការទទួលខុសត្រូវជាទូទៅ លើការងាររដ្ឋបាលមូលដ្ឋាន និងជំរុញកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋានស្របទៅនឹងមាត្រា៤២ មាត្រា៤៣ និង មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- កាត់បន្ថយភាពខុសគ្នាអំពី សក្តានុពលក្នុងការប្រមូលចំណូលផ្ទាល់រវាងឃុំ សង្កាត់នានា ដោយសារស្ថានភាពអាចនឹងផ្សេងគ្នា លើល័ក្ខខ័ណ្ឌភូមិសាស្រ្ត សេដ្ឋកិច្ច សង្គម និង ប្រជាសាស្រ្ត
- ជួយលើកទឹកចិត្តដល់ការកសាងសមត្ថភាពសំរាប់ការងារអភិបាលកិច្ចល្អរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៣.-

គណនីមូលនិធិឃុំ សង្កាត់ត្រូវបើកនៅរតនាគារជាតិ ។

គណនីមូលនិធិឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំង:

ក-ផ្នែកចំណូល:

- ការចូលរួមមួយចំណែក ពីចំណូលចរន្តនៃថវិការដ្ឋ
- ការចូលរួមពីជំនួយឥតសំណង និងការខ្ចីដែលបានមកពីម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា
- ការចូលរួមពីប្រភពផ្សេងៗទៀត ។

ខ-ផ្នែកចំណាយ:

- ការផ្ទេរប្រចាំឆ្នាំ ទៅក្នុងថវិកាឃុំ សង្កាត់

ចំណូលនៃមូលនិធិទាំងឡាយណាដែលមិនបានផ្ទេរក្នុងឆ្នាំ ត្រូវយោងទៅឆ្នាំបន្ទាប់ ។

ជំពូកទី ២
ការគ្រប់គ្រងមូលនិធិឃុំ សង្កាត់

មាត្រា ៤.-

ក្រុមប្រឹក្សាភិបាលមួយត្រូវបានបង្កើតឡើង ដោយអោយឈ្មោះថា ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ហៅកាត់ថា "ក្រុមប្រឹក្សាភិបាលមូលនិធិ" ។

ក្រុមប្រឹក្សាភិបាលមូលនិធិនេះ មានភារៈទទួលខុសត្រូវដូចខាងក្រោម :

- ផ្តល់យោបល់ ជូនរាជរដ្ឋាភិបាលអំពីចំណែកនៃចំណូលចរន្ត ដែលត្រូវចូលរួមក្នុងមូលនិធិ
- តាមដានលំហូរធនធានទៅក្នុងមូលនិធិដែលបានមកពីជំនួយឥតសំណង និងការខ្ចី ព្រមទាំងលើកគោលដៅជូនរាជរដ្ឋាភិបាលក្នុងការគៀងគរធនធានពីក្រៅប្រទេស
- អនុម័តលើរូបមន្តបែងចែកធនធាននៃមូលនិធិ ព្រមទាំងស្នើឡើងនូវអនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូររូបមន្តដែលមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ
- អនុម័ត និងធ្វើការកែសំរួលប្រចាំឆ្នាំនូវចំណាត់ថ្នាក់នៃឃុំ សង្កាត់ ដើម្បីវិភាជន៍ដល់សមាសភាគនៃមូលនិធិដូចមានចែងនៅក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ
- អនុម័តផែនការប្រចាំឆ្នាំលើការបែងចែកធនធាននៃមូលនិធិដោយផ្អែកលើចំណាត់ថ្នាក់និងរូបមន្តខាងលើ
- ប្រកាសជូនឃុំ សង្កាត់នូវធនធានត្រូវទទួលបានប្រចាំឆ្នាំ និងធ្វើការព្យាករណ៍ធនធានដែលឃុំ សង្កាត់ ត្រូវទទួលបានសំរាប់រយៈពេលបីឆ្នាំទៅមុខ
- តាមដានការផ្ទេរធនធានមូលនិធិជាក់ស្តែងទៅឃុំ សង្កាត់ ប្រៀបធៀបទៅនឹងផែនការបែងចែកប្រចាំឆ្នាំ
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃមូលនិធិ

ក្រុមប្រឹក្សាភិបាលត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ក្នុងរង្វង់មួយខែ ចាប់ពីថ្ងៃនៃការបង្កើតរបស់ខ្លួន ។

មាត្រា ៥.-

ក្រុមប្រឹក្សាភិបាលមូលនិធិមានសមាសភាពដូចខាងក្រោម:

- តំណាងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
- តំណាងក្រសួង មហាផ្ទៃ មួយរូប ជាសមាជិក
- តំណាងក្រសួង ផែនការ មួយរូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មួយរូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ដែលមកពីតំបន់មានកំរិតអភិវឌ្ឍន៍ខុសៗគ្នា ជ្រើសរើសដោយក្រសួងមហាផ្ទៃ ចំនួនបីរូប ជាសមាជិក

មាត្រា ៦.-

ក្រុមប្រឹក្សាភិបាលមូលនិធិមានលេខាធិការដ្ឋានមួយ ដែលត្រូវបង្កើតឡើងក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ លេខាធិការដ្ឋាននេះ មានភារៈទទួលខុសត្រូវដូចខាងក្រោម:

- សម្របសម្រួល និងធ្វើកំណត់ហេតុរាល់កិច្ចប្រជុំ ពិភាក្សារបស់ក្រុមប្រឹក្សាភិបាលមូលនិធិ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំត្រីមាសស្តីពីប្រតិបត្តិការនៃមូលនិធិ

- ផ្តល់រាល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាភិបាលមូលនិធិ ។

មាត្រា ៧.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានភារៈទទួលខុសត្រូវដូចខាងក្រោម:

- បញ្ជាការផ្ទេរធនធានទាំងអស់ ពីគណនីមូលនិធិទៅគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នីមួយៗ បន្ទាប់ពីបានផ្ទៀងផ្ទាត់ថាឃុំ សង្កាត់ដែលត្រូវទទួលនោះបំពេញបាននូវល័ក្ខខ័ណ្ឌនានាដូចមានចែងនៅក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ
- តាមដានការផ្ទេរមូលនិធិ និងការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់លើការប្រើប្រាស់ធនធានមូលនិធិ
- ផ្តល់ដល់ក្រុមប្រឹក្សាភិបាលមូលនិធិនូវពត៌មានលំអិតតាមកាលកំណត់ស្តីពីការផ្ទេរ និងប្រើប្រាស់ធនធាននៃមូលនិធិ ។

ក្នុងការបំពេញភារកិច្ចខាងលើ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើសកម្មភាពស្របតាមគោលការណ៍នានាដែលបានពិភាក្សាព្រមព្រៀងគ្នារបស់ក្រុមប្រឹក្សាភិបាលមូលនិធិ ។

មាត្រា ៨.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ដើម្បី:

- តាមដាន និងបញ្ជាក់លើការបំពេញបានត្រឹមត្រូវនូវល័ក្ខខ័ណ្ឌប្រើប្រាស់មូលនិធិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបញ្ជាក់ក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ
- តាមដានការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រើប្រាស់ធនធានមូលនិធិ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំបទប្បញ្ញត្តិទាំងឡាយដើម្បីណែនាំដល់ អភិបាលខេត្ត ក្រុង ក្នុងការបំពេញមុខងារខាងលើ ។

ជំពូកទី ៣
ការធ្វើហិរញ្ញប្បទាន ការវិភាជន៍ និង ការប្រើប្រាស់មូលនិធិ

មាត្រា ៩.-

អនុលោមតាមមាត្រា៧៧ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កំរិតនៃការផ្ទេរពីចំណូលចរន្តនៃថវិកាជាតិ រដ្ឋទៅក្នុងគណនីមូលនិធិត្រូវគ្រោងឡើងសំរាប់ថេរៈវេលាយ៉ាងតិចចំនួន៣ឆ្នាំថវិកា។

ឆ្នាំថវិកា២០០២ កំរិតនៃការផ្ទេរពីថវិការដ្ឋបានកំណត់ក្នុងមាត្រា២០ ជំពូក៥ អន្តរប្បញ្ញត្តិនៃ អនុក្រឹត្យនេះ។

ឆ្នាំថវិកា២០០៣ និង ២០០៤ កំរិតនៃការផ្ទេរពីថវិការដ្ឋទៅក្នុងគណនីមូលនិធិ បានគ្រោងឡើងជាភាគរយដូចខាងក្រោម:

- ឆ្នាំថវិកា២០០៣: មិនតិចជាង២,០% (ពីរភាគរយ) នៃចំណូលចរន្ត
- ឆ្នាំថវិកា២០០៤: មិនតិចជាង២,៥% (ពីរក្បៀសប្រាំភាគរយ) នៃចំណូលចរន្ត។

រាជរដ្ឋាភិបាលត្រូវគិតគូរដល់ការបង្កើនភាគរយនេះនៅពេលមានសំណើពីក្រុមប្រឹក្សាភិបាលមូលនិធិ ។

មាត្រា ១០.-

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវកំណត់គោលដៅប្រចាំឆ្នាំ ដើម្បីគៀងគរការចូលរួមពីក្រៅប្រទេសទៅក្នុងមូលនិធិ ។ គណនីប្រាក់បញ្ញើមួយជារូបិយប័ណ្ណរបស់មូលនិធិឃុំ សង្កាត់ ត្រូវបានបើកនៅធនាគារជាតិនៃកម្ពុជា ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទទួលធនធានពីជំនួយឥតសំណង និងការខ្ចីដែលម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាចូលរួម ។

ចំណូលរបស់មូលនិធិឃុំ សង្កាត់ក្នុងគណនីនៅធនាគារជាតិនៃកម្ពុជា ត្រូវផ្ទេរជាប្រាក់រៀលទៅគណនីរបស់មូលនិធិនៅរតនាគារជាតិនៅពេលណាដែលត្រូវការ ។

មាត្រា ១១.-

ចំណែកនៃធនធានមូលនិធិសរុបដែលអាចផ្ទេរទៅឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយរូបមន្តមួយ ។ រូបមន្តនេះត្រូវស្របទៅនឹងគោលបំណងនៃមូលនិធិ ដូចមានចែងនៅក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវអនុម័តរូបមន្តនិងប្រកាសពីចំនួនធនធានដែលឃុំ សង្កាត់នីមួយៗនឹងទទួលបានសំរាប់ឆ្នាំបន្ទាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែតុលា នៃឆ្នាំថវិកា ។

មាត្រា ១២.-

ធនធានសរុបនៃមូលនិធិត្រូវបានបែងចែកជាពីរសមាសភាគដូចខាងក្រោម :

- សមាសភាគរដ្ឋបាលទូទៅ មិនត្រូវច្រើនជាង ១ ភាគ ៣ នៃធនធានមូលនិធិសរុប
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន មិនត្រូវតិចជាង ២ ភាគ ៣ នៃធនធានមូលនិធិសរុប ។

ក្រុមប្រឹក្សាភិបាលមូលនិធិ ត្រូវកំណត់វិធីក្នុងការបែងចែកធនធានមូលនិធិសរុបដល់សមាសភាគទាំងពីរតាមកំរិតកំណត់ខាងលើ ។

មាត្រា ១៣.-

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំចំណាត់ថ្នាក់ឃុំ សង្កាត់ ជា ២ ប្រភេទ:

ប្រភេទទី១: រួមមានឃុំ សង្កាត់ដែលក្រុមប្រឹក្សាភិបាលមូលនិធិយល់ឃើញថាមានសមត្ថភាព និងលទ្ធភាពក្នុងការប្រើប្រាស់ធនធានមូលនិធិដែលបានផ្ទេរសំរាប់ចំណាយអភិវឌ្ឍន៍ល្អប្រសើរ និងមានប្រសិទ្ធភាព ។

ប្រភេទទី២: រួមមាន ឃុំ សង្កាត់ដែលគ្មាននៅក្នុងប្រភេទទី១ ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំ និងអនុម័តនូវផែនការពហុឆ្នាំដើម្បីបង្កើនជាបណ្តើរៗចំនួនឃុំ សង្កាត់ទៅក្នុងប្រភេទទី១ ។

ផ្អែកលើផែនការខាងលើ និងអោយបានមុនថ្ងៃទី០១ខែតុលារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវពិនិត្យចំនួនឃុំ សង្កាត់ដែលមានលក្ខណសម្បត្តិសមស្របគួរបញ្ចូលក្នុងប្រភេទទី១ ។

មាត្រា ១៤.-

ធនធានទាំងឡាយ នៃសមាសភាគទាំងពីររបស់មូលនិធិត្រូវបានបែងចែក និង ប្រើប្រាស់តាមការកំណត់ខាងក្រោមៈ

ក) ធនធាននៃសមាសភាគរដ្ឋបាលទូទៅ

- អាចប្រើប្រាស់ដោយឃុំ សង្កាត់នៅក្នុងប្រភេទទី១ និងប្រភេទទី២
- ត្រូវបែងចែកតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ
- អាចអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចំណាយប្រតិបត្តិការ ឬវិនិយោគផ្នែករដ្ឋបាលដែលសមស្របដូចបានកំណត់នៅក្នុងមាត្រា ១៥ នៃអនុក្រឹត្យនេះ ។

ខ) ធនធាន នៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន

- អាចប្រើប្រាស់បានតែក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងប្រភេទទី១
- ត្រូវគណនាចេញជាបីចំណែកៈ ចំណែកស្មើគ្នាជាមូលដ្ឋាន ចំណែកសមាមាត្រទៅនឹងប្រជាពលរដ្ឋ និងចំណែកសមាមាត្រទៅនឹងសន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ
- អនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះតែលើចំណាយអភិវឌ្ឍន៍ ដូចបានកំណត់នៅក្នុងមាត្រា១៥ នៃអនុក្រឹត្យនេះ ។

ក្រសួងផែនការត្រូវផ្តល់អោយក្រុមប្រឹក្សាភិបាលមូលនិធិអោយបានមុនថ្ងៃទី០១ ខែកញ្ញា នៃឆ្នាំនីមួយៗនូវការប៉ាន់ស្មានចុងក្រោយអំពី :

- ចំនួនប្រជាពលរដ្ឋសរុប នៃ ឃុំ សង្កាត់ នីមួយៗ
- សន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ

មាត្រា ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ថវិកាផ្ទេរពីមូលនិធិឃុំ សង្កាត់សំរាប់ចំណាយមួយផ្នែកឬ ទាំងស្រុងលើវិនិយោគ និងប្រតិបត្តិការ ដែលឆ្លុះបញ្ចាំងនៅក្នុងថវិកាដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងមិនផ្ទុយទៅនឹងច្បាប់ និងលិខិតបទដ្ឋានទាំងឡាយជាធរមាន។

ការចំណាយរដ្ឋបាល គឺជាចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តនីភារកិច្ចរដ្ឋបាលទូទៅរបស់ខ្លួន ។ ចំណាយនេះរួមមាន :

- ប្រាក់បំណាច់ សំរាប់ក្រុមប្រឹក្សា ឃុំ សង្កាត់
- បៀវត្សមន្ត្រី ឃុំ សង្កាត់ និង ចំណាយផ្សេងៗដល់មន្ត្រី បុគ្គលិកទាំងនោះ
- ការទិញ ឬ ការជួលទីតាំងសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់
- សម្ភារៈ និង ឧបករណ៍ការិយាល័យឬ មធ្យោបាយសំភារៈរដ្ឋបាល សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់

- ការជួសជុល និង ការថែទាំមធ្យោបាយសំភារៈរដ្ឋបាល
- ថ្លៃប្រើប្រាស់ទឹក និង អគ្គិសនី
- ទិញ ឬ ជួលយានជំនិះ
- ប្រេងឥន្ធនៈ ប្រេងរំអិល និងការ ថែទាំយានជំនិះ
- ចំណាយផ្សេងៗ

ចំណាយអភិវឌ្ឍន៍គឺជាចំណាយប្រតិបត្តិការ និង ចំណាយវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន (លើកលែងមធ្យោបាយសំភារៈរដ្ឋបាល) និងការផ្តល់សេវាសេដ្ឋកិច្ចសង្គមនៅឃុំ សង្កាត់ (លើកលែង រដ្ឋបាល) ។ ចំណាយទាំងនោះរួមមាន :

- ការអង្កេត គំនូសប្លង់ ការសាងសង់ ការជួសជុល និង ការថែទាំផ្លូវ ផ្សារ មណ្ឌលសុខភាព សាលារៀន មជ្ឈមណ្ឌល សហគមន៍ សំណង់ប្រព័ន្ធធារាសាស្ត្រ ឃ្លាំងផ្ទុកកសិផល ប្រព័ន្ធផ្គត់ផ្គង់ទឹក និង ថាមពល និង ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គម ផ្សេងទៀត ។

- ចំណាយលើមន្ត្រីបុគ្គលិកនិងចំណាយចរន្តដែលពាក់ព័ន្ធនឹងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវា

- ចំណាយគាំទ្រកម្មវិធីអភិវឌ្ឍន៍សហគមន៍ ដែលចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន និងអង្គការជួយសហគមន៍ រួមបញ្ចូលនូវយុទ្ធនាការផ្តល់ពត៌មាន និង អប់រំសំរាប់ស្ត្រី និង យុវជននៅមូលដ្ឋាន ការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីដទៃដែលមានឥទ្ធិពលដល់សុខុមាលភាពសង្គម និងប្រជាពលរដ្ឋនៅមូលដ្ឋាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសេចក្តីណែនាំលំអិតមួយ ដោយផ្សារភ្ជាប់ទៅនឹងបទបញ្ញត្តិស្តីពីថវិកាឃុំ សង្កាត់ ដើម្បីធ្វើយ៉ាងណាអោយប្រភេទរដ្ឋបាលនិងអភិវឌ្ឍន៍មានភាពរលូនទៅនឹងចំណាត់ថ្នាក់ចំណាយនៅក្នុងថវិកា ។

ជំពូកទី ៤
នីតិវិធីនៃការផ្ទេរ និង លក្ខខ័ណ្ឌទទួលបានធនធានមូលនិធិ

មាត្រា ១៦.-

ឃុំ សង្កាត់ទាំងអស់ត្រូវមានគណនីប្រាក់បញ្ញើមួយនៅរតនាគារខេត្ត ក្រុង ឬ នៅធនាគារពាណិជ្ជណាមួយដែលមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

អនុលោមតាមមាត្រា៧នៃអនុក្រឹត្យនេះ និងតាមសំណើរបស់ក្រសួងមហាផ្ទៃ រតនាគារជាតិត្រូវផ្ទេរថវិកាវិភាជន៍ដែលបានអនុម័តប្រចាំឆ្នាំទៅគណនីរបស់ឃុំ សង្កាត់នីមួយៗ នៅរតនាគារខេត្ត ក្រុង ឬ ធនាគារពាណិជ្ជ ។

6

ថវិកាផ្ទេរប្រចាំឆ្នាំត្រូវធ្វើឡើងជាបីលើក: ការផ្ទេរលើកទី១គឺ ៥០%(ហាសិបភាគរយ)នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ០១ ខែមីនា លើកទី២គឺ ៣០%(សាមសិបភាគរយ)នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ០១ខែមិថុនា និងលើកទី៣ ចំនួននៅសល់ ២០%(ម្ភៃភាគរយ)ត្រូវផ្ទេរអោយបានមុនថ្ងៃទី ០១ ខែកញ្ញា ។

មាត្រា ១៧.-

ដើម្បីទទួលបានការផ្ទេរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជាក់ថាខ្លួនបាន:

- អនុវត្តតាមវិធីចូលរួមក្នុងដំណើរការ ធ្វើផែនការ ថវិកា និង ការងារប្រតិបត្តិ
- បំពេញរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍ថវិកា និង ផែនការអភិវឌ្ឍន៍របស់ខ្លួន ។
- ប្រមូលទុនចូលរួមរបស់មូលដ្ឋាន ព្រមទាំងធនធានដទៃទៀតរបស់មូលដ្ឋានដើម្បីបំពេញបន្ថែមលើការផ្ទេរពីមូលនិធិ នៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ។

ក្នុងរយៈពេល ២០ ថ្ងៃ ពីថ្ងៃទទួលបានពាក្យសុំផ្ទេរថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុង ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវ:

- ផ្ទៀងផ្ទាត់លើការអនុវត្តន៍ល័ក្ខខ័ណ្ឌទាំងឡាយដើម្បីទទួលបានធនធានមូលនិធិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ ទៅក្រសួងមហាផ្ទៃ លើការបំពេញបានសព្វគ្រប់នៃការផ្ទេរធនធាន

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់មិនបំពេញបានចំពោះល័ក្ខខ័ណ្ឌ អភិបាលខេត្ត ក្រុងត្រូវជួយផ្តល់យោបល់ និងណែនាំ សកម្មភាព កែតំរូវ និងផ្តល់ជំនួយបច្ចេកទេសចាំបាច់ ។ បន្ទាប់មកអភិបាលខេត្ត ក្រុង ត្រូវស្នើយោបល់ទៅក្រសួងមហាផ្ទៃ ដើម្បីផ្អាកការផ្ទេរសិនរហូតដល់កង្វះខាតដែលស្នើអោយកែតំរូវខាងលើត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់បំពេញតាមត្រឹមត្រូវ ។

ក្នុងករណីមានបាតុភាពមិនចុះសំរុងគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់និងអភិបាលខេត្ត ក្រុងនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនបញ្ហានេះទៅក្រុមប្រឹក្សាភិបាលមូលនិធិដើម្បីពិនិត្យ និងសំរេច ។ ការសំរេចរបស់ក្រុមប្រឹក្សាភិបាលមូលនិធិចាត់ទុកជា សេចក្តីសំរេចចុងក្រោយបង្អស់ ។

ជំពូកទី ៥

អន្តរប្បញ្ញត្តិ

មាត្រា ១៨.-

ក្នុងពេលដែលក្រុមប្រឹក្សាភិបាលមូលនិធិមិនទាន់បង្កើតឡើង គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវធានាអនុវត្តមាត្រា ៤ នៃអនុក្រឹត្យនេះ ដោយមានអនុគណៈកម្មការកិច្ចការហិរញ្ញវត្ថុជាជំនួយការ ។

មាត្រា១៩.-

ក្នុងអាណត្តិរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវធ្វើអនុសាសន៍ និងរាយការណ៍ជាទៀងទាត់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្ដីពីប្រតិបត្តិការរបស់មូលនិធិ ។ បទប្បញ្ញត្តិ ព្រមទាំងសេចក្ដីណែនាំ ឬបទបញ្ជាទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការ របស់មូលនិធិត្រូវដាក់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ពិនិត្យសំរេច ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំ និងដាក់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ អនុម័តផែនការពហុឆ្នាំ ក្នុងរយៈពេល៦ខែបន្ទាប់ពីត្រូវបានបង្កើតឡើង ដើម្បីបង្កើនជាបណ្ដើរៗនូវចំនួនឃុំទៅក្នុងប្រភេទទី១ ។

មាត្រា ២០.-

សំរាប់ឆ្នាំថវិកា២០០២ ការផ្ទេរពីថវិការដ្ឋទៅក្នុងមូលនិធិឃុំ សង្កាត់ មានចំនួន ២០.០០០.០០០.០០០៛ (ម្ភៃពាន់លានរៀល) ។

មាត្រា ២១.-

ឃុំ សង្កាត់ដែលត្រូវបញ្ចូលទៅក្នុងប្រភេទទី១ ក្នុងឆ្នាំថវិកា ២០០២ គឺឃុំ សង្កាត់ទាំងឡាយណាដែលមានផែនការអភិវឌ្ឍន៍របស់ខ្លួន មានសមត្ថភាព លទ្ធភាព ក្នុងការប្រើប្រាស់មូលនិធិសំរាប់អភិវឌ្ឍន៍បានល្អប្រសើរ និងមានប្រភពហិរញ្ញប្បទានជាក់លាក់ ។

មាត្រា ២២.-

ឆ្នាំថវិកា២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានទទួលការផ្ទេរមូលនិធិលើកទី១ និងលើកទី២ ដោយមិនបាច់បំពេញល័ក្ខខ័ណ្ឌ ។ ក្រសួងមហាផ្ទៃ ត្រូវចេញសេចក្ដីណែនាំ និងទំរង់របាយការណ៍សំរាប់អនុវត្តការផ្ទេរលើកទី៣ អោយបានមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០២ ។

ជំពូកទី ៦
អវសានប្បញ្ញត្តិ

មាត្រា២៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា២៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ស ខេង យូ ហុកគ្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*

II.D.PSB.24

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០០ អនក្រ-តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីការទូត

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង លោក **សូ សីខ្មា** បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូនៈ

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១០១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៥៥*៥៥

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបន្ទាយមានជ័យ

សំរេច

មាត្រា ១ :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនលោក **ម៉ក់ ពីត្ន** និងលោកស្រី **អ៊ុង ណាពី** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ១០៥.៣០០ ដុល្លារអាមេរិក ដើម្បីរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិ ជួយឧបត្ថម្ភដល់ស្នងការនគរបាលខេត្ត និង ជួយកសាងវិហារឥស្លាមចំនួន ០៣ ខ្នង នៅស្រុកសិរីសោភ័ណ និង ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស ំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន **៦៩០ គ្រឿង** ជូនមន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម ៖

ក- **<u>មេដាយមាសការងារ ចំនួន ១០ រូប</u> :**

១- ឯកឧត្តម គុំ សារ៉ុន	អគ្គនាយក នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២- លោក សាន វណ្ណទី	អគ្គនាយករង នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
៣- លោក សៅ សំបូរ	អគ្គាធិការរង នៃអគ្គាធិការដ្ឋាន

៤- លោក ជឹម ងួន — អគ្គនាយករង នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
៥- លោក ស៊ុង វ៉ា — ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
៦- លោក ណៅ ធូក — ប្រធាននាយកដ្ឋានជលផល
៧- លោក កៅ ផល់ — ប្រធាននាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល
៨- លោក កែវ សេង — ប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម
៩- លោក ស៊ឹម ហង្ស — ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
១០- លោក ញឹម ចន្ទ័ថេត — ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

ខ‑ មេដាយថ្នាក់ការងារ ចំនួន ៣៧ រូប :

១- លោក ថុច មេងឃាង — អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល
២- លោក គិត សេង — អនុប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
៣- លោក សេន សុវណ្ណ — អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល
៤- លោក សួន សុធឿន — អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល
៥- លោក ស៊ីវ ញ៉ាន — អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល
៦- លោក ម៉ៅ សាមី — អនុប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម
៧- លោក ញ៉ែម សុខា — អនុប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម
៨- លោក ឈឹម សូមាន — អនុប្រធាននាយកដ្ឋានផែនការ នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
៩- លោក គង់ សេរី — អនុប្រធានមន្ទីរ នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
១០- លោក ហាស់ សុខ — អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១១- លោក ប៉ែន វុធ — អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម
១២- លោក ថាយ ស៊ុនហ៊ាង — នាយកសាលាកសិកម្មព្រែកលៀប
១៣- លោក សំ សារ៉ន — នាយកសាលាកសិកម្មកំពង់ចាម
១៤- លោក ជា សារ៉េត — អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
១៥- លោក មាស ពិសិដ្ឋ — នាយករង វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
១៦- លោក សម នៅ — អនុប្រធាននាយកដ្ឋានជលផល
១៧- លោក អេង ជាសាន — អនុប្រធាននាយកដ្ឋានជលផល
១៨- លោក អ៊ឹង ទ្រី — អនុប្រធាននាយកដ្ឋានជលផល

១៩- លោក ផាត់ លេង	ប្រធានមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ
២០- លោក ជឹម សុខខុន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្ដាល
២១- លោក ថាច់ រតនា	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្វាយរៀង
២២- លោក អ៊ិត សារុន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ
២៣- លោក យឹម សុខា	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត
២៤- លោក ប៊ិន សារ៉េត	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ
២៥- លោក ឈុត សុធោន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង
២៦- លោក គង់ ឈឿន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម
២៧- លោក នៅ រតនា	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុងព្រះសីហនុ
២៨- លោក ណុប គីម	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុងកែប
២៩- លោក ទិត សំអឿន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិសាត់
៣០- លោក កៅ ថុងហួ	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យ
៣១- លោក តាត ប៊ុនឈឿន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប
៣២- លោក ឯម ភាណ	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ
៣៣- លោក ប៉ែន វុទ្ធី	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ
៣៤- លោក ហួត ថុង	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកោះកុង
៣៥- លោក និន ចាន់សាមឿន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង
៣៦- លោក ប៉ែន ម៉ារ៉ាន់ឌី	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ
៣៧- លោក ពុយ សុខហៃ	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ

គ- មេដាយសេរីវឌ្ឍនភាពខារ ចំនួន ៦៤៣ រូប :

១- លោក ឡាច ប៊ុនអ៊ួង	អនុប្រធានការិយាល័យបុគ្គលិក នៃនាយកដ្ឋានកិច្ចការរដ្ឋបាល
២- លោក ឆេង ឈុនលី	ប្រធានការិយាល័យសន្តិសុខ នៃនាយកដ្ឋានកិច្ចការរដ្ឋបាល
៣- លោក យឹម ខុន	មន្ត្រីរាជការ នាយកដ្ឋានកិច្ចការរដ្ឋបាល
៤- លោក យឹម សារុន	មន្ត្រីរាជការ នាយកដ្ឋានកិច្ចការរដ្ឋបាល
៥- លោក គឹម សុវណ្ណា	មន្ត្រីរាជការ នាយកដ្ឋានកិច្ចការរដ្ឋបាល
៦- លោក ឌុក អន	អ្នកបើកបរ នាយកដ្ឋានកិច្ចការរដ្ឋបាល
៧- លោក វង្ស ណារិទ្ធ	មន្ត្រីរាជការ នាយកដ្ឋានកិច្ចការរដ្ឋបាល
៨- លោក ណុប សុផៃ	មន្ត្រីរាជការ នាយកដ្ឋានកិច្ចការរដ្ឋបាល

៩- លោកស្រី ហ៊ូ គួយឃីម	ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១០- លោក ប៉ោ រតនា	អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១១- លោក ហង់ ជូនចំរ៉ុង	អនុប្រធានការិយាល័យផែនការ នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១២- លោក ឡេង ជ្រាង	អនុប្រធានការិយាល័យផែនការ នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១៣- លោក ជី សុចិន្តា	មន្ត្រីរាជការ នាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១៤- លោក ព្រហ្ម សិទ្ធី	មន្ត្រីរាជការ នាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១៥- លោក ចឹក ណាន់	ប្រធានការិយាល័យស្ថិតិ នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១៦- លោក ស្រី វុឌ្ឍី	ប្រធានការិយាល័យទីផ្សារកសិកម្ម នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១៧- លោកស្រី អ៊ួង ហេង	ប្រធានការិយាល័យកំណត់តំបន់កសិកម្ម នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១៨- លោក អ៊ុន កុសល	អនុប្រធានការិយាល័យអាស៊ានកសិកម្ម នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
១៩- លោក ម៉ក់ ម៉ូនី	មន្ត្រីរាជការ នាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
២០- លោក អឿន ពិសិដ្ឋ	អនុប្រធានផ្នែកអង្គភាពជីកសិកម្ម នៃនាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ
២១- លោក លឹម ជីគង់	មន្ត្រីរាជការ អគ្គាធិការដ្ឋាន
២២- លោក គីម ហួរ	មន្ត្រីរាជការ អគ្គាធិការដ្ឋាន
២៣- លោក អ៊ុន អយ	ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានជលផល
២៤- លោក ភឿន ភាន	ប្រធានការិយាល័យកិច្ចការដែននេសាទ នៃនាយកដ្ឋានជលផល

២៥- លោក ពុំ សុថា ប្រធានស្នាក់ការសមុទ្រ នៃនាយកដ្ឋានជលផល
២៦- លោក ឡុង ឈាង ប្រធានការិយាល័យផែនការគណនេយ្យ នៃនាយកដ្ឋានជលផល
២៧- លោក ឡុង គន ប្រធានការិយាល័យអធិការកិច្ច នៃនាយកដ្ឋានជលផល
២៨- លោក ស្រ៊ុន លឹមសុង ប្រធានការិយាល័យវារីវប្បកម្ម នៃនាយកដ្ឋានជលផល
២៩- លោក ខាត់ សុឃន ប្រធានស្ថានីយ៍ស្រាវជ្រាវជលផល នៃនាយកដ្ឋានជលផល
៣០- លោក ចាប់ ចាន់ដឺរ៉ា អនុប្រធានការិយាល័យផែនការគណនេយ្យ នៃនាយកដ្ឋានជលផល
៣១- លោក សន ចាន់ ប្រធានស្នាក់ការចតុមុខ នៃនាយកដ្ឋានជលផល
៣២- លោក ចាប សៀកហេង ប្រធានស្នាក់ការទន្លេសាប នៃនាយកដ្ឋានជលផល
៣៣- លោក ស៊ុន សុធី ប្រធានស្នាក់ការមេគង្គ នៃនាយកដ្ឋានជលផល
៣៤- លោក ស៊ូ សាខន អនុប្រធានការិយាល័យវិវាទ នៃនាយកដ្ឋានជលផល
៣៥- លោក ហេង សុថារិទ្ធ អនុប្រធានការិយាល័យអាជីវកម្ម នៃនាយកដ្ឋានជលផល
៣៦- លោក រស់ វុទ្ធី អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានជលផល
៣៧- លោក ញ៉ែម អុន អនុប្រធានស្នាក់ការទន្លេសាប នៃនាយកដ្ឋានជលផល
៣៨- លោក ប៉ែន ផានិរិទ្ធ អនុប្រធានការិយាល័យអធិការកិច្ច នៃនាយកដ្ឋានជលផល
៣៩- លោក វ៉ង់ វ៉ាន់សុខែម មន្ត្រីរាជការ នាយកដ្ឋានជលផល
៤០- លោក ពេជ ប៊ុនណា មន្ត្រីរាជការ នាយកដ្ឋានជលផល
៤១- លោក ងួន គីមឈន មន្ត្រីរាជការ នាយកដ្ឋានជលផល
៤២- លោក ញឹម ស៊ីនួន មន្ត្រីរាជការ នាយកដ្ឋានជលផល
៤៣- លោក ស៊ិន វិសិទ្ធ មន្ត្រីរាជការ នាយកដ្ឋានជលផល
៤៤- លោក យូ ទិត្យផាណូ មន្ត្រីរាជការ នាយកដ្ឋានជលផល
៤៥- លោក អ៊ុច វុត្ថា មន្ត្រីរាជការ នាយកដ្ឋានជលផល
៤៦- លោក អ៊ិន ហ៊ុល មន្ត្រីរាជការ នាយកដ្ឋានជលផល
៤៧- លោក លី គួង មន្ត្រីរាជការ នាយកដ្ឋានជលផល
៤៨- លោក ជិន ដា មន្ត្រីរាជការ នាយកដ្ឋានជលផល
៤៩- លោក ហាវ ពិសិដ្ឋ មន្ត្រីរាជការ នាយកដ្ឋានជលផល
៥០- លោក ឡុញ វុទ្ធី មន្ត្រីរាជការ នាយកដ្ឋានជលផល
៥១- លោក ឡាង គីរី មន្ត្រីរាជការ នាយកដ្ឋានជលផល
៥២- កញ្ញា ថាច់ ណារីផល មន្ត្រីរាជការ នាយកដ្ឋានជលផល

៥៣- អ្នកស្រី ព្រំ បុណ្ណមី មន្ត្រីរាជការ នាយកដ្ឋានជលផល

៥៤- អ្នកស្រី រុន សុវណ្ណដារី មន្ត្រីរាជការ នាយកដ្ឋានជលផល

៥៥- លោក ហែម រ៉ាឌី មន្ត្រីរាជការ នាយកដ្ឋានជលផល

៥៦- លោក ធ សែន សេរីវឌ្ឍន៍ មន្ត្រីរាជការ នាយកដ្ឋានជលផល

៥៧- លោក ញាណ ចូច មន្ត្រីរាជការ នាយកដ្ឋានជលផល

៥៨- លោក សួង សុផល មន្ត្រីរាជការ នាយកដ្ឋានជលផល

៥៩- លោក ឯក ហេង មន្ត្រីរាជការ នាយកដ្ឋានជលផល

៦០- លោក នេត ឈុនអ៊ីម មន្ត្រីរាជការ នាយកដ្ឋានជលផល

៦១- លោក ស៊ីវ ចយ មន្ត្រីរាជការ នាយកដ្ឋានជលផល

៦២- លោក យិន ណន មន្ត្រីរាជការ នាយកដ្ឋានជលផល

៦៣- លោក សម សិរី មន្ត្រីរាជការ នាយកដ្ឋានជលផល

៦៤- អ្នកស្រី អ៊ុម សោភណៈ មន្ត្រីរាជការ នាយកដ្ឋានជលផល

៦៥- លោក ប៉ែន សុត ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក នៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

៦៦- លោក សុក ហ៊ាង អនុប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក នៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

៦៧- លោក យូ សារិន មន្ត្រីរាជការ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

៦៨- លោក ហួត សម្បត្តិ ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

៦៩- លោក ណាប់ សុខហ៊ីម ប្រធានការិយាល័យបសុព្យាបាល នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

៧០- លោក កែវ ជានី ប្រធានស្ថានីយ៍គោភ្នំតាម៉ៅ នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

៧១- លោក ថាន់ សឿន អនុប្រធានការិយាល័យផលិតកម្ម នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

៧២- លោក គង់ សិរិទ្ធ អនុប្រធានស្ថានីយ៍គោភ្នំតាម៉ៅ នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

៧៣- លោក អ៊ុច សុខុម អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋាន

	ផលិតកម្ម និងបសុព្យាបាល
៧៤- លោក ប៊ូ ធឿន	អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៧៥- លោក ផាន់ ចាន់ចុល	អនុប្រធានការិយាល័យផែនការគណនេយ្យ នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៧៦- លោក ស៊ាន កុសល	អនុប្រធានការិយាល័យផែនការគណនេយ្យ នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៧៧- លោក ម៉ៅ ដារ៉ុធ	អនុប្រធានការិយាល័យបសុព្យាបាល នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៧៨- លោក លឹម ចាន់ធី	អនុប្រធានការិយាល័យផលិតកម្ម នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៧៩- កញ្ញា ពេជ ពិទូរ្យរដ្ឋា	អនុប្រធានការិយាល័យផ្សព្វផ្សាយ នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨០- លោក វ៉ែន សូវឿន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨១- លោក អ៊ុង សេរីវុឌ្ឍ	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨២- កញ្ញា វ៉ា សុផល	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨៣- អ្នកស្រី អ៊ី សារូន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨៤- កញ្ញា ខៀវ បូរានី	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨៥- លោក និល សុខុម	អ្នកបើកបរ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨៦- លោក ថន សូវីរ៉ា	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨៧- លោក ស៊ិន ប៉ោ	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨៨- លោកស្រី សំ វួច	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៨៩- លោក ង៉ែត សុខន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩០- កញ្ញា ជួន ពុទ្ធារី	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩១- លោក ស៊ន សាន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩២- លោក ញ៉ែម សំអឿន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩៣- លោក កែវ សំណាង	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

៩៤- លោក អ៊ិន សុផារី	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ៩៥-
លោក ហ៊ល ដារ៉ុន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩៦- លោក ហ៊ូ វណ្ណារ៉ា	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩៧- លោក ទូច ម៉ាន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩៨- លោក សែម ស៊ិញ	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
៩៩- លោក ឡុច ពៅ	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០០- លោក គីម សារ៉េត	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០១- លោក ប៊ូ ចក់	អ្នកបើកបរត្រាក់ទ័រ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០២- លោក អោម វ៉េត	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០៣- អ្នកស្រី ទី អៀមនី	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០៤- អ្នកស្រី ទេព វ៉ាន់នី	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០៥- លោក ស្រេង ងន	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០៦- អ្នកស្រី ម៉ាក់ ណេង	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០៧- លោក គា ផា	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០៨- កញ្ញា សែម សោភា	មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
១០៩- លោក សុខ ឡេង	ប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១០- លោក ហែម ថុន	ប្រធានការិយាល័យផែនការគណនេយ្យ នៃនាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១១- លោក ហួត ឈុនលីម	ប្រធានការិយាល័យអប់រំផ្សព្វផ្សាយ នៃនាយកដ្ឋានគ្រឿង-យន្តកសិកម្ម
១១២- លោក យឿង ស៊ីណា	ប្រធានការិយាល័យបុគ្គលិក នៃនាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១៣- លោក ចាប ឈួម	អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១៤- លោក សរ ស្រ៊ុន	អនុប្រធានការិយាល័យគ្រប់គ្រងគំរោង នៃនាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១៥- លោក ទូច ឃុន	ប្រធានការិយាល័យស្រាវជ្រាវបច្ចេកទេស នៃនាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១៦- អ្នកស្រី រ៉ិត សុជាតិ	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១៧- លោក វង្ស ផល្លា	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម

១១៨- លោក កុយ ផល	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១១៩- លោក អ៊ុង យស់	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២០- លោក ថោង រចនា	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២១- លោក សេង សារ៉ាត	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២២- លោក គង់ ថន	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២៣- លោក ជេត ឌុំ	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២៤- លោក សួង វ៉ង	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២៥- លោក តុក យាង	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២៦- លោក គីម សុគីម	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២៧- លោក ឃួន សាមុត្រ	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២៨- លោក ស៊ិន វ៉ា	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១២៩- លោក ប៉ែន នៅ	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១៣០- លោក អ៊ូ តិចលី	មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម
១៣១- លោក ឡាយ សារ៉េត	ប្រធានការិយាល័យរដ្ឋបាល នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
១៣២- អ្នកស្រី ជួប សារិន	ប្រធានការិយាល័យបេឡវត្ស នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
១៣៣- លោក ហង់ គន្ធា	ប្រធានការិយាល័យផែនការ នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
១៣៤- លោក អៀម សារិទ្ធ	អនុប្រធានការិយាល័យបច្ចេកទេស នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
១៣៥- លោក រស់ សំណាង	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៣៦- លោក នុត តារា	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៣៧- លោក ម៉ាក ជា	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៣៨- អ្នកស្រី តូ យ៉ូវ៉ានី	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៣៩- អ្នកស្រី ហួន ចន្ទ័នី	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៤០- អ្នកស្រី ស្វាយ ឆវី	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៤១- អ្នកស្រី យោគ សាម៉ុល	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៤២- អ្នកស្រី ហែន ចាន់ណារី	មន្ត្រីរាជការ អគ្គនាយកដ្ឋានចំការកៅស៊ូ
១៤៣- អ្នកស្រី យស់ សាងកានី	ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋាន ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៤៤- លោក កុយ វុត្ថា	អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋាន

	ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៤៥- លោក គាត សាយ	អនុប្រធានការិយាល័យផែនការគណនេយ្យ នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៤៦- លោក ហ៊ាន វណ្ណបាន	ប្រធានការិយាល័យការពារដំណាំ នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៤៧- លោក ប៊ុន ទូនស៊ីម៉ូណា	អនុប្រធានការិយាល័យការពារដំណាំ នៃនាយកដ្ឋានក្សេត្រ-សាស្ត្រ និងកែលំអដីកសិកម្ម
១៤៨- លោក ម៉ាក់ សឿន	ប្រធានការិយាល័យបច្ចេកទេស នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៤៩- លោក ហូ ពុទ្ធា	អនុប្រធានការិយាល័យបច្ចេកទេស នៃនាយកដ្ឋានក្សេត្រ-សាស្ត្រ និងកែលំអដីកសិកម្ម
១៥០- លោក ខាន់ សំបាន	ប្រធានការិយាល័យដំណាំឧស្សាហកម្ម នៃនាយកដ្ឋានក្សេត្រ-សាស្ត្រ និងកែលំអដីកសិកម្ម
១៥១- លោក សៅ ចេស្តា	អនុប្រធានការិយាល័យដំណាំឧស្សាហកម្ម នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិម្ម
១៥២- លោក សរ សារ៉ាត	អនុប្រធានកសិដ្ឋានទួលសំរោង នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៥៣- លោក ម៉ុង វ៉ាន់ឌី	អនុប្រធានស្ថានីយ៍ក្បាលកោះ នៃនាយកដ្ឋានក្សេត្រសាស្ត្រ
១៥៤- លោក សួន សើរ	ប្រធានកសិដ្ឋានផលិតពូជស្រូវ កប់ស្រូវ នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៥៥- លោក កែវ សារឿន	អនុប្រធានមជ្ឈមណ្ឌលកប់ស្រូវ នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
១៥៦- លោក សេង សារ៉ុន	ប្រធានការិយាល័យគណៈនេយ្យ នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
១៥៧- លោកស្រី ភីម សុវណ្ណនី	មន្ត្រីរាជការ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
១៥៨- លោក ស៊ូ លន់	មន្ត្រីរាជការ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
១៥៩- លោក គីម ដារ៉ា	ប្រធានការិយាល័យអប់រំផ្សព្វផ្សាយ នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

១៦០- លោក ធន់ សៀងហេង	ប្រធានការិយាល័យផែនការគណនេយ្យ នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
១៦១- លោក កៅ សុត	មន្ត្រីរាជការ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
១៦២- លោក ឌុង ស៊ីវណ្ណា	មន្ត្រីរាជការ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
១៦៣- កញ្ញា ទៀង ម៉ារីន	មន្ត្រីរាជការ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
១៦៤- លោក ស៊ិន កុសល	អនុប្រធានការិយាល័យនីតិកម្មវិវាទ នៃនាយកដ្ឋានរុក្ខា-ប្រមាញ់
១៦៥- លោក ឌី សុខុម	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៦៦- លោក រស់ កណ្ណារ៉ា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៦៧- លោក នូ ថារិទ្ធ	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៦៨- លោក ឱម មាក់ធារី	អនុប្រធានការិយាល័យកិច្ចការរំព្រៃឈើ នៃនាយកដ្ឋានរុក្ខា-ប្រមាញ់
១៦៩- លោក មាក់ ហ៊ាង	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧០- លោក ហុង ណារីត	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧១- លោក ប៊ុន វណ្ណា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧២- លោក ប៊ូរី ពិសិដ្ឋ	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧៣- លោក ដេត សីលា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧៤- លោក ស រ៉ោ	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧៥- លោក ហួរ លីមឈុន	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧៦- លោក ឡាវ សេដ្ឋាផល	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧៧- លោក នុព សុធា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧៨- លោក ញឹក ស៊ុនណារី	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៧៩- លោក គង់ ពុទ្ធីរ៉ា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨០- លោក មាគ វុំឌ្បី	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨១- លោក ង៉ី វិរៈ	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨២- លោក នួន ពៅរតនា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨៣- លោក លាវ ប៊ុនថុន	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨៤- លោក ជា ប៊ុនថា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨៥-លោក គង់ ភាជ	អនុប្រធានក្រុមហ៊ុនកាំហ្វ៊ីចស៊ីម នៃនាយកដ្ឋានរុក្ខា-ប្រមាញ់
១៨៦- លោក ហ៊ុន អៀង	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់

១៨៧- លោក ចាន់រិទ្ធី	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨៨- លោក សូ លន	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៨៩- លោក នូវ ប៉ោលីន	អនុប្រធានការិយាល័យវិស្វកម្មព្រៃឈើ នៃនាយកដ្ឋានរុក្ខា-ប្រមាញ់
១៩០- លោក ហួត សារឿន	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៩១- លោក នៃ សារ៉ាន់	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៩២- លោក សូ ធា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៩៣- លោក ផាន់ ភីន	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៩៤- លោក ឆាង ភូរិទ្ធ	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៩៥- លោក ចេង សុផេង	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៩៦- លោក ប៉ក់ ចន្ទ័បូរ៉ា	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
១៩៧- អ្នកស្រី ឈិន សំអាង	មន្ត្រីរាជការ នាយកដ្ឋានរុក្ខា-ប្រមាញ់
